វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី៣១ ខែឧសភាឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះគឺ៖

- កម្ពុជា ស្ថិតក្នុងចំណោមប្រទេសដែលតភ្ជាប់បណ្តាញអគ្គិសនីបានលឿនជាងគេក្នុងពិភពលោក
- ប្រទេសជាសមាជិកអាស៊ាន នឹងអាចទទួលបានផលចំណេញពីសង្គ្រាមពាណិជ្ជកម្មពិភពលោក
- អាមេរិកបានធ្លាក់មកនៅលំដាប់ទី៣នៅក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចដែលមានភាពប្រកួតប្រជែងបំផុត

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលតភ្ជាប់បណ្តាញអគ្គិសនីបានលឿនជាងគេក្នុងពិភពលោក

យោងតាមរបាយការណ៍ ស្តីពីវឌ្ឍនភាពថាមពលរបស់ធនាគារពិភពលោកឆ្នាំ២០១៩ បានបង្ហាញថា កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសលើពិភពលោក ដែលមានលទ្ធភាពតភ្ជាប់បណ្តាញអគ្គិសនីបានលឿនជាងគេ ដែលមានកំណើនក្នុងអត្រា ៨,៣% ជាមធ្យមក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ២០១៧។ របាយការណ៍នេះបានប៉ាន់ស្មានថា សេវាគ្របដណ្តប់អគ្គិសនីប្រទេសកម្ពុជា ឈានដល់អត្រា ៨៩,១% គិតត្រឹមចុងឆ្នាំ ២០១៧។ នៅតំបន់ទីប្រជុំជន ការប្រើប្រាស់បណ្តាញអគ្គិសនីដោយពឹងលើបណ្តាញជាតិមានអត្រា ៩៧% ចំណែកតំបន់ជនបទ ការប្រើប្រាស់អគ្គិសនីតាមរយៈបណ្តាញជាតិមានប្រមាណ៦៧% និងការប្រើប្រាស់ដោយមិនពឹងលើបណ្តាញជាតិមាន ៣១%។

នៅចុងឆ្នាំ២០១៨ ការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជាបានឈានដល់ ២ ៦៥០ មេហ្គាវ៉ាត់ និងមានផែនការបង្កើនទៅដល់ ២ ៨៧០ មេហ្គាវ៉ាត់នៅឆ្នាំ២០១៩ ដោយផ្អែកលើរបាយការណ៍របស់អាជ្ញាធរអគ្គិសនីកម្ពុជា (EAC)។

### តារាងប្រចាំសប្តាហ៍៖ សមាសភាគ នៃចំណាយមូលធន ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩

ចំណាយមូលធនរបស់កម្ពុជាពីត្រីមាសទី១ ឆ្នាំ២០១៥ ដល់ត្រីមាសទី១ឆ្នាំ២០១៩ មានប្រភពចម្បងពីជំនួយបរទេស ដែលមានកម្រិតទាបត្រឹម ៥០% នៅឆ្នាំ២០១៨ នឹងកម្រិតខ្ពស់ ៧៣% នៅឆ្នាំ ២០១៥។

នៅត្រីមាសទី១ ក្នុងឆ្នាំ២០១៩ ជំនួយពីខាងក្រៅមានចំនួនរហូតដល់ជិត ៨០%នៃចំណាយមូលធនសរុប។

### ជំនួយពីបរទេស និងហិរញ្ញប្បទានក្នុងស្រុក (គិតជា%)




ប្រភព៖ [ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ]

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### សមាជិកអាស៊ាន នឹងអាចទទួលបានផលចំណេញពីសង្គ្រាមពាណិជ្ជកម្មពិភពលោក

យោងតាមសារព័ត៌មានអាស៊ានប៉ុស្តិ៍បានអោយដឹងថា ខណៈដែលសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន បានគំរាមកំហែងដល់សេដ្ឋកិច្ចជាសកល សេដ្ឋកិច្ចអាស៊ានអាចនឹងទទួលបានឱកាស និងការរីកចម្រើនសំខាន់ៗមួយចំនួន។ ទីតាំងភូមិសាស្រ្តរបស់អាស៊ាន ខ្សែសង្វាក់ផ្គត់ផ្គង់រឹងមាំ បណ្តាញចែកចាយជាសកល ទំហំកម្លាំងពលកម្មជាមួយនឹងថ្លៃដើមកំលាំងពលកម្មទាប និងទំនាក់ទំនងមិត្តភាពជាមួយប្រទេសចិន និងសហរដ្ឋអាមេរិក ជាកត្តាដែលបណ្តាប្រទេសជាសមាជិករបស់ខ្លួន ដើរតួជាអន្តរការីរវាងមហាអំណាចសេដ្ឋកិច្ចទាំងពីររបស់ពិភពលោក។

ខណៈដែលការយកពន្ធនាំចូលរវាងប្រទេសចិន និងសហរដ្ឋអាមេរិកមានការកើនឡើង ក្រុមហ៊ុននានានឹងបង្កើនការមើលឃើញបណ្តាប្រទេសនៅអាស៊ាន ជាគោលដៅដែលមានកម្រិតពន្ធទាបក្នុងការដាក់ទីតាំងផលិតកម្ម និងចែកចាយ។ ក្រុមហ៊ុនវាយនភ័ណ្ឌ និងស្បែកជើងមួយចំនួន បានស្វែងរកជម្រើសផ្សេងៗដើម្បីប្តូរទីតាំងពីប្រទេសចិនទៅកាន់តំបន់អាស៊ាន។ ការវិនិយោគដែលបានចុះបញ្ជីថ្មីៗ នៅប្រទេសវៀតណាមបានកើនឡើង៨១% ហើយដើមទុនដើម្បីផ្តល់មូលនិធិលើគម្រោងថ្មីៗក៏បានកើនឡើង ២១៥%ក្នុងឆ្នាំ២០១៩។

ប្រទេសម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងកម្ពុជាក៏ជាគោលដៅដែលបានទទួលការចាប់អារម្មណ៍ខ្លាំង ក្នុងការសម្រេចចិត្តលើទីតាំងវិនិយោគផងដែរ។

## សេដ្ឋកិច្ចពិភពលោក

### អាមេរិកបានធ្លាក់មកនៅលំដាប់ទី៣ នៅក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចដែលមានភាពប្រកួតប្រជែងបំផុត

ចំណាត់ថ្នាក់ការប្រកួតប្រជែងជាសកលឆ្នាំ២០១៩ របស់សាលាធុរៈកិច្ច IMD បានផ្តល់ឲ្យប្រទេសសឹង្ហបុរីនូវចំណាត់ថ្នាក់ខ្ពស់បំផុត ដោយយោងតាមសូចនាការប្រកួតប្រជែងធុរៈកិច្ចចំនួនបួន ដែលទាក់ទងទៅនឹងស្ថានភាពសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ប្រសិទ្ធភាពរបស់រដ្ឋាភិបាល និងប្រសិទ្ធភាពអាជីវកម្ម។ ប្រទេសសឹង្ហបុរីបានឈានមុខ ហុងកុង និងសហរដ្ឋអាមេរិក។

សហរដ្ឋអាមេរិកបានធ្លាក់ចុះទៅលំដាប់ទីបី ដោយសារតែគោលនយោបាយពន្ធដែលគ្មានលក្ខណៈប្រកួតប្រជែង ការកើនឡើងតម្លៃប្រេង ភាពចុះខ្សោយការនាំចេញដែលប្រើបច្ចេកវិទ្យាខ្ពស់ និងផលប៉ះពាល់នៃសង្គ្រាមពាណិជ្ជកម្មលើការប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចរបស់ខ្លួន។

កត្តាដែលជួយជំរុញអោយសឹង្ហបុរីទទួលបានចំណាត់ថ្នាក់ល្អរួមមាន៖ ច្បាប់អន្តោប្រវេសន៍របស់សឹង្ហបុរី ហេដ្ឋារចនាសម្ព័ន្ធដែលមានបច្ចេកវិទ្យាទំនើប កម្លាំងពលកម្មជំនាញ និងប្រសិទ្ធភាពក្នុងការបង្កើតអាជីវកម្មថ្មី។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អតិផរណារបស់ប្រទេសហ្វីលីពីន និងកូរ៉េខាងត្បូង និងអត្រានិកម្មភាពនៅក្នុងតំបន់អឺរ៉ុប និងសហរដ្ឋអាមេរិក។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី០៣ ខែ មិថុនា

- ចំណាយមូលធនរបស់ជប៉ុនសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- តុល្យភាពពាណិជ្ជកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែមេសា
- ចំណាយលើផ្នែកសំណង់របស់អាមេរិក សម្រាប់ខែមេសា

ថ្ងៃអង្គារ ទី០៤ ខែមិថុនា

- អតិផរណារបស់កូរ៉េខាងត្បូង សម្រាប់ខែឧសភា
- ផ.ស.ស.របស់កូរ៉េខាងត្បូង សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- ផលិតកម្មឧស្សាហកម្មរបស់ហ្វីលីពីន សម្រាប់ខែមេសា
- អតិផរណារបស់ថៃ សម្រាប់ខែឧសភា
- តុល្យភាពថវិការបស់បារាំង សម្រាប់ខែមេសា
- និកម្មភាពនៅក្នុងតំបន់អឺរ៉ុប សម្រាប់ខែមេសា

ថ្ងៃពុធ ទី០៥ ខែមិថុនា

- ទុនបំរុងរូបិយប័ណ្ណបរទេសរបស់កូរ៉េខាងត្បូង សម្រាប់ខែឧសភា
- គណនីចរន្តរបស់កូរ៉េខាងត្បូង សម្រាប់ខែមេសា
- ផ.ស.ស. របស់អូស្ត្រាលី សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- អតិផរណារបស់ហ្វីលីពីន សម្រាប់ខែឧសភា
- និកម្មភាពរបស់ហ្វីលីពីន សម្រាប់ត្រីមាសទី២ ឆ្នាំ ២០១៩

ថ្ងៃព្រហស្បតិ៍ ទី០៦ ខែមិថុនា

- ការវិនិយោគភាគហ៊ុនដោយជនបរទេសរបស់ជប៉ុន សម្រាប់ខែមិថុនា
- ទំនុកចិត្តអាជីវកម្មនៅថៃ សម្រាប់ខែឧសភា
- ផ.ស.ស. នៅតំបន់អឺរ៉ុប សម្រាប់ត្រីមាសទី១ ឆ្នាំ ២០១៩
- តុល្យភាពពាណិជ្ជកម្មរបស់អាមេរិក សម្រាប់ខែមេសា

ថ្ងៃសុក្រ ទី០៧ ខែមិថុនា

- ទុនបំរុងរូបិយប័ណ្ណបរទេសរបស់ឥណ្ឌូនេស៊ី សម្រាប់ខែឧសភា
- បៀវត្ស វិស័យមិនមែនកសិដ្ឋាន នៅអាមេរិក សម្រាប់ខែឧសភា
- ការចំណាយប្រចាំគ្រួសាររបស់ជប៉ុន សម្រាប់មេសា
- ទុនបំរុងរូបិយប័ណ្ណបរទេសសឹង្ហបុរី សម្រាប់ខែឧសភា